**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១០ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១ / នស / ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងប្រទេស

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំ រេ ច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១:** អនុក្រឹត្យនេះ មានទិសដៅកំណត់នូវប្រាក់របបឧបត្ថម្ភជីវភាពដល់មន្ត្រីរាជការដែលមានភារៈកិច្ចបំពេញការងារ បេសកកម្ម ក្នុងនិងក្រៅប្រទេស ។

### ជំពូកទី២

### ក្រុមខំណមន្ត្រីរាជការដែលត្រូវបានទទួលប្រាក់របបបេសកកម្ម

**មាត្រា២:** មន្ត្រីរាជការដែលត្រូវបានទទួលរបបបេសកកម្មក្នុង និង ក្រៅប្រទេស គឺជាមន្ត្រីរាជការដែលកំពុងកាន់មុខតំណែងពិតប្រាកដ នៅក្នុងអង្គការលេខ នៃរចនាសម្ព័ន្ធរបស់ក្រសួង និង ស្ថាប័នរដ្ឋ ។

**មាត្រា៣:** មន្ត្រីរាជការទាំងឡាយដូចមាត្រា២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជីវភាពក្នុងពេលបំពេញការងារបេសកកម្មទៅតាម ឋានន្តរស័ក្តិនៃមុខតំណែង និង ទីកន្លែងបំពេញការងារ ។

### ជំពូកទី៣

### អំពីប្រាក់របបឧបត្ថម្ភ

### I-បេសកកម្មក្នុងប្រទេស

**មាត្រា៤:** ប្រាក់របបឧបត្ថម្ភជីវភាពក្នុងកិច្ចបំពេញការងារបេសកកម្មត្រូវបានកំណត់ដូចតទៅ:

ក : ប្រាក់របបពិសេសសំរាប់មន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការ អគ្គនាយក ឬ មន្ត្រីថ្នាក់ស្មើនឹងមុខតំណែងនេះ ឡើងទៅ :

| សោហ៊ុយចំណាយបេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់/ថ្ងៃឬយប់ | ផ្សេងៗ |
|---|---|---|
| -ប្រាក់ហោប៉ៅ | ១៦.០០០៛០០ | ✱ក្នុងទីក្រុងភ្នំពេញ ឬ ក្នុងទីក្រុងតាមខេត្តក្រុងនានា មិនផ្តល់ជូនទេ |
| -ហូបចុក | ៣០.០០០៛០០ | ✱បេសកកម្មរយៈពេលខ្លី: ធ្វើដំណើរដោយមធ្យោបាយរបស់រដ្ឋ និងមិនសំរាក |
| -ស្នាក់នៅ | ៨០.០០០៛០០ | ពេលយប់ ផ្តល់ជូនតែប្រាក់បេសកកម្ម និងប្រាក់ហូបចុក ។ |

ខ : ប្រាក់របបបេសកកម្មសំរាប់មន្ត្រីរាជការទូទៅ មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការរង អគ្គនាយករង ឬមន្ត្រីថ្នាក់ស្មើនឹង មុខតំណែងនេះចុះក្រោម :

| សោហ៊ុយចំណាយបេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់ | | | | | | | រយៈពេល |
|---|---|---|---|---|---|---|---|---|
| | ក្នុងទីក្រុងភ្នំពេញ ឬ ក្នុងទីក្រុងតាមខេត្តក្រុងនានា | សំរាប់ក្នុងទឹកដីខេត្ត-ក្រុងដែលមានចំងាយផ្លូវ | | សំរាប់ក្នុងទឹកដីខេត្តភូមិភាគឥសានដែលមានចំងាយផ្លូវ | | បេសកកម្មឆ្លងខេត្តក្រុងដែលមានចំងាយផ្លូវ | | |
| | | ពី១០ ដល់ ៤០គ.ម | លើសពី៤០គ.ម | ពី៥ដល់ ៣០គ.ម | លើសពី៣០គ.ម | ពី១០ ដល់ ៤០គ.ម | លើសពី៤០គ.ម | |
| -ប្រាក់ហោប៉ៅ | មិនផ្តល់ជូនទេ | ៨.០០០៛០០ | ៨.០០០៛០០ | ៨.០០០៛០០ | ៨.០០០៛០០ | ៨.០០០៛០០ | ៨.០០០៛០០ | ១ថ្ងៃ |
| -ហូបចុក | -ដ- | ១៥.០០០៛០០ | ១៥.០០០៛០០ | ១៥.០០០៛០០ | ១៥.០០០៛០០ | ១៥.០០០៛០០ | ១៥.០០០៛០០ | ១ថ្ងៃ |
| -ស្នាក់នៅ | -ដ- | មិនផ្តល់ជូនទេ | ៤០.០០០៛០០ | មិនផ្តល់ជូនទេ | ៤០.០០០៛០០ | មិនផ្តល់ជូនទេ | ៤០.០០០៛០០ | ១យប់ |

គ : ប្រាក់របបបេសកកម្មដោយឡែកសំរាប់ការប្រជុំថ្នាក់អន្តរជាតិស្ថិតនៅក្នុងខេត្ត-ក្រុង ក្រៅពីខ្ទួនរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានកំណត់:

| សោហ៊ុយចំណាយបេសកកម្ម | របបឧបត្ថម្ភក្នុងម្នាក់ | | រយៈពេល | ផ្សេងៗ |
|---|---|---|---|---|
| | មន្ត្រីជាន់ខ្ពស់(១) | មន្ត្រីរាជការទូទៅ(២) | | |
| - ប្រាក់ហោប៉ៅ | ៣២.០០០៛០០ | ១៦.០០០៛០០ | ១ថ្ងៃ | ✱ប្រាក់បេសកកម្មនេះមិនគិតចូលក្នុង |
| -ហូបចុក | ៦០.០០០៛០០ | ៣០.០០០៛០០ | ១ថ្ងៃ | គំរោងចំណាយនៃកម្មវិធីប្រជុំទេ ។ |
| -ស្នាក់នៅ | ៣០០.០០០៛០០ | ២០០.០០០៛០០ | ១យប់ | (១) ឋានៈដូចមាត្រា ៤.ក |
| | | | | (២) ឋានៈដូចមាត្រា ៤.ខ |

## II -បេសកកម្មនៅបរទេស

**មាត្រា៥:** គណៈប្រតិភូកម្ពុជា ឬ មន្ត្រីរាជការដែលត្រូវបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ឬពីក្រសួងស្ថាប័នសាមី តាមការអញ្ជើញរបស់ប្រទេសភាគីមិត្ត ត្រូវកំណត់ជូនតាមឋានន្តរៈស័ក្តិនៃមុខដំណែងដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ជា ៤ ប្រភេទ ដូចខាងក្រោម :

ប្រភេទ ក : សមាជិករាជរដ្ឋាភិបាល

ប្រភេទ ខ : មន្ត្រីជាន់ខ្ពស់រួមមាន ថ្នាក់អនុរដ្ឋលេខាធិការ អគ្គលេខាធិការរាជរដ្ឋាភិបាល អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ អគ្គនាយក ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ឬថ្នាក់ស្មើនឹងមុខដំណែងនេះ ។

ប្រភេទ គ : មន្ត្រីមានឋានៈជាវរៈមន្ត្រី អនុមន្ត្រី នាយក្រមការ រួមមាន ថ្នាក់អគ្គលេខាធិការរង ឬអគ្គនាយករង ចុះមកត្រឹមថ្នាក់ប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល និងអនុប្រធានមន្ទីរខេត្ត-ក្រុង ឬ ថ្នាក់ស្មើមុខដំណែងនេះ ។

ប្រភេទ ឃ : មន្ត្រីថ្នាក់ក្រមការដើមខ្សែ និងមន្ត្រីរាជការក្នុងក្របខ័ណ្ឌរដ្ឋចាប់ពីថ្នាក់អនុប្រធានការិយាល័យនៅរដ្ឋបាលកណ្តាល និង ប្រធានការិយាល័យនៅមន្ទីរខេត្ត-ក្រុង ឬ ថ្នាក់ស្មើនឹងមុខដំណែងនេះចុះក្រោម ។

**មាត្រា៦** : ប្រាក់របបបេសកកម្មសំរាប់ចំណាយក្នុងកិច្ចបំពេញការងារក្រៅប្រទេស ត្រូវកំណត់ជូនជារូបិយប័ណ្ណ ( ប្រាក់ដុល្លារអាមេរិក) តាមប្រភេទដូចខាងក្រោម :

ឯកត្តាគិត : ដុល្លារអាមេរិក

| ប្រភេទនៃមុខដំណែងមន្ត្រីរាជការ | របបឧបត្ថម្ភក្នុងម្នាក់-ថ្ងៃ | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រាក់ហោប៉ៅ | ប្រាក់ហូបចុក | | | ប្រាក់ស្នាក់នៅ | | |
| | | អាស៊ី | អឺរ៉ុប-អាហ្វ្រិក | អាមេរិក-អូស្ត្រាលី-ជប៉ុន | អាស៊ី | អឺរ៉ុប-អាហ្វ្រិក | អាមេរិក-អូស្ត្រាលី-ជប៉ុន |
| -ប្រភេទ ក | ៥០ | ៨០ | ១០០ | ១២០ | ២៥០ | ៣៥០ | ៤០០ |
| -ប្រភេទ ខ | ៤០ | ៧០ | ៨០ | ១០០ | ២០០ | ២៥០ | ៣០០ |
| -ប្រភេទ គ | ៣០ | ៦០ | ៧០ | ៨០ | ១៥០ | ២០០ | ២០០ |
| -ប្រភេទ ឃ | ២០ | ៦០ | ៧០ | ៨០ | ១៥០ | ២០០ | ២០០ |

**មាត្រា៧** : ចំណាយផ្សេងៗ ដោះស្រាយជូនក្នុងកំរិតមួយសមស្របដោយផ្អែកតាមគំរោងរបស់ក្រសួងនិងស្ថាប័នស្នើសុំចំណាយ ។

**មាត្រា៨** : វត្ថុអនុស្សាវរីយ៍ ដោះស្រាយជូនតែប្រតិភូដែលមានប្រធានដឹកនាំមានឋានៈចាប់ពីឧត្តមមន្ត្រីឡើងលើ ដូចក្នុងមាត្រា៥ ត្រង់ប្រភេទ ក និងប្រភេទ ខ ។

**មាត្រា៩** : សហព័ទ្ធអមដំណើរ( បើមាន) សោហ៊ុយចំណាយទាំងអស់ជាបន្ទុករបស់សាមីជន ។ រដ្ឋទទួលបន្ទុកតែចំណាយរបស់សហព័ទ្ធអមដំណើរដែលជាភរិយារបស់នាយករដ្ឋមន្ត្រី ឬឧបនាយករដ្ឋមន្ត្រីដែលបំពេញទស្សនកិច្ចផ្លូវរដ្ឋក្នុងនាមនាយករដ្ឋមន្ត្រី ។

## ជំពូកទី៤

## អំពីទិដ្ឋាការនៃការសន្យាចំណាយនិងការទូទាត់

**មាត្រា១០: ទិដ្ឋាការនៃការសន្យាចំណាយ** ចាំបាច់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបរិបថចំណាយហិរញ្ញវត្ថុសាធារណៈ ដូចមានខ្លឹមសារចែងក្នុងជំពូកទី១ មាត្រា៣ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។ ដូចនេះ ចំណាយលើរបបបេសកកម្មក្នុងឬក្រៅប្រទេស ទោះបីជាមានភាពចាំបាច់និងបន្ទាន់ ឬមួយក៏ប្រតិភូបានវិលត្រឡប់ដោយមិនបានសុំទិដ្ឋាការនៃការសន្យាចំណាយជាមុន អាណាប័កមិនមានសិទ្ធិបោះផ្សាយអាណត្តិបើកប្រាក់( សន្យាចំណាយទាំងស្រុង) តែម្តងបានទេ បើគ្មានការស្នើសុំជាលាយល័ក្ខអក្សរ និងមានទិដ្ឋាការនៃការ សន្យាចំណាយ( យល់ព្រម) ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនទេនោះ ។

**មាត្រា១១: ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេស :**

ការទូទាត់ចំណាយបេសកកម្មក្នុងប្រទេសត្រូវអនុវត្តជាប្រាក់រៀលតាមរបបបានកំណត់នៅក្នុងមាត្រា៤ ខាងលើ ទោះបីមានសក្ខីប័ត្រចំណាយខ្លះជារូបិយប័ណ្ណបរទេសក៏ដោយ ។

សោហ៊ុយធ្វើដំណើរ ( ក្នុងករណីគ្មានមធ្យោបាយរបស់រដ្ឋ) ដោះស្រាយជូនតាមវិក័យប័ត្រជាក់ស្តែង ។

ប្រាក់បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ថ្ងៃ ។ បើលើសពីនេះ ចាំបាច់ត្រូវមានបញ្ជាបេសកកម្មបន្ត តែក៏មិនឱ្យលើសពី ២០ថ្ងៃ ក្នុង ១ខែ ។

ប្រាក់ហូបចុកឬក៏មានចំណាយផ្សេងៗបន្ថែមទៀត ត្រូវកត់ត្រាក្នុងខ្ទង់ថវិកាជំពូក ១១.០២.០១.០៣ " សោហ៊ុយស្នាក់នៅ " ។ ក្នុងករណីចំណាយបេសកកម្មនេះមានចំនួនទឹកប្រាក់មិនលើសពីកំរិតកំណត់នៃរជ្ជទេយ្យបុរេប្រទានទេនោះ ត្រូវប្រើប្រាស់ឥណទានថវិកាក្នុងរជ្ជទេយ្យបុរេប្រទាន ។

**មាត្រា១២** : ការទូទាត់ចំណាយ**បេសកកម្មនៅបរទេស :**

-សោហ៊ុយធ្វើដំណើរ ដោះស្រាយជូនតាមតម្លៃក្នុងវិក័យប័ត្រ ឬវិក័យប័ត្របណ្ដោះអាសន្ន *(Proforma Invoice)* ដោយគិតរួមបញ្ចូលទាំងថ្លៃបង់ពន្ធព្រលានយន្តហោះ ។ ថ្លៃសំបុត្រយន្តហោះត្រូវបែងចែកជាបីប្រភេទ តាមឋានៈដូចខាងក្រោម :

១- នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី កំណត់ថ្លៃសំបុត្រយន្តហោះថ្នាក់ទី ១ *(First Class)* ។

២- រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមន្ត្រីមានមុខដំណែងណាមួយក្នុងប្រភេទ ខ កំណត់ថ្លៃសំបុត្រយន្តហោះ ថ្នាក់ជំនួញ *(Business Class)* ។

៣- ប្រធានប្រតិភូនិងសមាជិករួមដំណើរដូចក្នុងប្រភេទ គ-ឃ កំណត់ថ្លៃសំបុត្រយន្តហោះថ្នាក់ធម្មតា *(Economic Class)* ។ បើសិនរយៈពេល ហោះហើរចាប់ពីប្រាំមួយ(០៦)ម៉ោងឡើង ថ្លៃសំបុត្រយន្តហោះសំរាប់ប្រធានប្រតិភូ កំណត់ជូនថ្នាក់ជំនួញ *(Business Class)* ។

-ប្រាក់បេសកកម្មកំណត់ខ្ពស់បំផុតត្រឹម ១០ថ្ងៃ ។

-ប្រាក់បេសកកម្ម បើរយៈផ្លូវឆ្ងាយត្រូវឆ្លងកាត់ច្រើនដំណាក់ចាប់ពីពីរ(០២)ថ្ងៃឡើង ប្រាក់ឧបត្ថម្ភលើសោហ៊ុយស្នាក់នៅ ហូបចុក និងប្រាក់ដាក់ហោប៉ៅត្រូវកំណត់ជូនបន្ថែមត្រឹមមួយថ្ងៃទៅ-មួយថ្ងៃមក ។

-សោហ៊ុយចំណាយសំរាប់សហព័ទ្ធអមដំណើរដូចក្នុងមាត្រា៩(បើមាន) ដោះស្រាយជូនតែសោហ៊ុយធ្វើដំណើរនិងប្រាក់ហូបចុកប៉ុណ្ណោះ ។

-ដោយឡែក សោហ៊ុយបេសកកម្មសំរាប់នាយករដ្ឋមន្ត្រី រួមទាំងសោហ៊ុយចំណាយផ្សេងៗ ដោះស្រាយជូនតាមគំរោងសមស្រប ។

-សរុបទឹកប្រាក់ចំណាយបេសកកម្មដែលទទួលបានទិដ្ឋាការសន្យាចំណាយរួចហើយ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់ជា**របបកំណត់ សំរាប់ផ្ដល់ថវិកាជូនតែម្ដង** ។

**មាត្រា១៣:** ករណីមុខចំណាយមួយចំនួនត្រូវបានទទួលការរ៉ាប់រងពីភាគីអញ្ជើញ មុខចំណាយនោះនឹងត្រូវកាត់ចេញ ពីរបបឧបត្ថម្ភលើសោហ៊ុយបេសកកម្មក្នុងឬក្រៅប្រទេស ។

ការទូទាត់ចំណាយសំរាប់ប្រាក់ហោប៉ៅ ពន្ធព្រលានយន្តហោះ និងចំណាយផ្សេងៗ (បើមាន) ត្រូវប្រើថវិកា**រជ្ជទេយ្យបុរេប្រទាន** ។

**មាត្រា១៤** : ករណីដោយឡែកដែលកម្មវិធីបេសកកម្ម ឬទស្សនៈកិច្ចនៅបរទេស**មានការប្រែប្រួលដោយថាហេតុ** ថវិកាផ្តល់បន្ថែមចាំបាច់ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ប៉ុន្តែ ទោះយ៉ាងនេះក្តី អាណាប័កត្រូវពិនិត្យនិង ទទួលស្គាល់ជាមុនពីភាពត្រឹមត្រូវនូវរាល់លិខិតយុត្តិការចំណាយដែលប្រតិភូបេសកកម្មបានបង្ហាញតាមរយៈរបាយការណ៍ ។

**មាត្រា១៥** : បេសកកម្មក្នុងឬក្រៅប្រទេសដែលក្រសួងនិងស្ថាប័ន**មិនបានសុំទិដ្ឋាការធានា ចំណាយជាមុន**ដូចក្នុង មាត្រា៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននីតិសម្បទាគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យតាមគ្រប់រូបភាពស្របច្បាប់នូវ ចំណាយថវិកាដែលមិនត្រឹមត្រូវ**តាមបរិបថហិរញ្ញវត្ថុ នេះ** ។

ក្រោយការពិនិត្យឃើញពីភាពត្រឹមត្រូវនៃលិខិតយុត្តិការពាក់ព័ន្ធព្រមទាំងមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ ការទូទាត់ចំណាយបេសកកម្មក្នុងនិងក្រៅប្រទេសរបៀបនេះនឹងប្រព្រឹត្តទៅតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន តែត្រូវធ្វើជាប្រាក់រៀលចំពោះបេសកកម្មក្រៅប្រទេស ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៦** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៧ ដើម្បីអនុវត្ត
- ឯកសារនិងកាលប្បវត្តិ